ឧបសោសង្ហា

# ឥទ្ធិពលព្រះអង្គម្ចាស់ក្សត្រីចូវ



គំនូរស្ត្រីយួន

# ពិនិត្យឡើងវិញនូវព្រឹត្តិការណ៍សំខាន់ៗមាននៅក្នុងប្រវត្តិសាស្ត្រខ្មែរ

**សង្ខេប សម្រួល ដកស្រង់ ពី ឯកសារ លោក អេង សុត និង អត្ថាធិប្បាយ ជាមតិផ្ទាល់**

## មាតិការឿង


**ព្រឹត្តិការណ៍ សំខាន់ៗ** .......... 2
**ព្រះអង្គក្សត្រីចូវ** .......... 14
**អត្ថាធិប្បាយ** .......... 21

ព្រះអង្គម្ចាស់ក្សត្រីចូវ ជាព្រះរាជបុត្រីព្រះចៅក្រុងហ្វេ។ ព្រះអង្គត្រូវជាព្រះទេពី ព្រះជ័យចេស្ដា ជាព្រះរាជបុត្រច្បង របស់ព្រះបាទសម្ដេចព្រះស្រីសុរិយោព័ណ៌ (១៦០០-១៦១៨)។

នៅឆ្នាំ ១៦០៥ បន្ទាប់មានសង្គ្រាម ជាមួយ នគរសៀម កន្លងមក ព្រះស្រីសុរិយោព័ណ៌[1] ទ្រង់ ជួបប្រជុំអស់ព្រះវង្សា មហាភិមុខមន្ត្រី ហើយទ្រង់ត្រាស់ថា : យើងរស់តែប្រាប់ប្រាមសឹកសង្គ្រាម ក្នុងរយះពេល ៥ ឆ្នាំ កន្លងមកនេះ ពុំទាន់បានគិត រៀបចំព្រះនគរ ឲបានត្រឹមត្រូវនៅឡើយទេ។ យើងយល់ថា ខាងក្រុងទេពបុរី ស្រីអយុធ្យា នគរសៀមនោះ តែងតែគិតមកពាធាបៀតបៀននគរយើងច្រើនគ្រា ច្រើនដងមកហើយ ដូច្នេះយើង គួរចងសម្ពន្ធមិត្ត និងព្រះចៅក្រុងហ្វេ ចងស្ពានព្រះរាជមេត្រី សុំយកព្រះអង្គម្ចាស់ក្សត្រីអង្គចូវ ឲបានមកផ្សំ ជាព្រះទេពីនឹង

[1] ព្រះបាទស្រីសុរិយោពណ៌ កាលដែលទព័សៀមវាយបន្ទាយលង្វែកបែក, ព្រះអង្គជាអហាឧបរាជ, ក្រោយពីហ្លួងខ្មែរ ជាព្រះរៀម លួចរត់ចេញពីបន្ទាយ, ព្រះអង្គ បានសុំចុះចាញ់សៀម។ ហើយ ពួកសៀម បានអញ្ជើញព្រះអង្គឲទៅគង់នៅស្រុកសៀម អស់បួនរាជ្យ ទើបពួកនាម៉ឺនសព្វមុខមន្ត្រីស្នែរ នាំគ្នាទៅអញ្ជើញព្រះអង្គ ឲយាងត្រឡប់មកសោយរាជ្យ នៅ ឆ្នាំ ១៦០០។ ពេលនោះព្រះអង្គមានព្រះជន្ម ៤៦ ព្រះវស្សា។ បន្ទាប់មក ស្រុកខ្មែរមានកើតចលាចល ជាខ្លាំង កើតមកពីការបះបោរ ប៉ុន្តែព្រះអង្គ ទ្រង់បានបង្ក្រាបឲរាបទៅវិញ។ ដោយសារមានការចលាចល សៀមក៏ឆ្លៀតយកឱកាសចូលមករុករានស្រុកខ្មែរ។ ប៉ុន្តែ ព្រះអង្គ ទ្រង់ច្បាំងតយុទ្ធទាល់តែបានជ័យជំនះ ហើយកងទ័ពសៀមក៏បាក់ទ័ពរត់ទៅវិញអស់ទៅ។

ព្រះជ័យចេស្ដា។ បើបានដូចសេចក្ដីប្រាថ្នា របស់យើងហើយ នគរសៀម ក៏គង់តែនឹកកោតញញើតយួនខ្លះ ពុំសូវនឹងគិតមកញាំញីនគរយើងពេក។

ព្រះចៅក្រុងហ្វេ ទទួល នូវសេចក្ដីស្នើពីមន្ត្រីទូតខ្មែរ ទ្រង់យល់ឃើញថា : ព្រះស្រីសុរិយោព័ណ៌ អង្គនេះល្បីល្បាញឮរន្ទឺព្រះជានុភាព ខាងការប្រាបប្រាមសឹកសត្រូវ ដ៏មាំមួនណាស់ ទាំងព្រះរាជហឫទ័យ ក៏ប្រកបដោយសុចរិត យុត្តិធម៌ណាស់ដែរ។ បើយើងព្រមសេចក្ដីសុំ របស់ហ្លួងខ្មែរ ស្រុកយួននឹងបានស្រុកខ្មែរ ជាពីរនគរ គួរសមចងស្ពានមានព្រះរាជមេត្រីបាន។

ព្រះចៅក្រុងហ្វេ យល់ព្រមតាមសេចក្ដីស្នើ ទើបទ្រង់ ឲរើសរកស្ត្រីយួនចំនួន ៥០០នាក់ ជាសាវឡិក[2] ឲរើសរកបុរស ៥០០នាក់ ដាក់ជាចំណងព្រះហស្ត ហើយឲចាស់ទុំអញ្ជើញសម្ដេចព្រះរាជបុត្រី និង បរិវារ ចុះសំពៅ ១៥ យាងមកក្រុងកម្ពុជា។ ចាប់ពីពេលនោះមក យួនបានចូលចេញព្រះនគរកម្ពុជាធិបតី បានដោយសេរី។

នៅឆ្នាំ ១៦២៨, ព្រះស្រីសុរិយោព័ណ៌ ទ្រង់ សោយរាជ្យសម្បត្តិ បាន ១៨ ឆ្នាំ ក៏កើត ព្រះទ័យនឿយណាយឡើង។ ទ្រង់ដាក់រាជ្យថ្វាយព្រះរាជបុត្រច្បង ព្រះនាមសម្ដេច ព្រះ

[2] ស្រីជំទងអ្នកបម្រើព្រះអង្គម្ចាស់ក្សត្រា ក្សត្រី។

ជ័យចេស្ដា ឬ ព្រះបាទជ័យជេដ្ឋា ទី២ (១៦១៨-១៦២៨) មានព្រះជន្ម ២៣ ឆ្នាំ ឡើងប្រារពជាភិសេក សោយរាជ្យ ស្នង សម្ដេចព្រះវររាជបិតា ហើយ តែងតាំង ព្រះអនុជ ព្រះនាម ព្រះឧទ័យ ជា មហាឧបរាជ។ ព្រះបាទជ័យជេដ្ឋាទី២ ទ្រង់លើកព្រះទេពីអង្គចូវ ជាព្រះអគ្គមហេសី ថ្វាយព្រះនាម សម្ដេចព្រះភគវតី ព្រះស្រីវរក្សត្រី។ បន្ទាប់មក ទ្រង់លើកព្រះរាជវាំងពី ល្វាឯម ទៅសាងនៅស្រុកឧដុង្គមានជ័យវិញ ព្រោះស្រុកនោះ ធំទូលាយ ហើយដរបាយខ្សាច់ភូរផង់ មិនដក់ទឹក។ ជាមួយ ព្រះអគ្គមហេសីចូវ ទ្រង់មានព្រះរាជបុត្រា ព្រះនាម តូ និង មាន ព្រះបុត្រាបុត្រីជាច្រើនទៀតជាមួយអ្នកនាងផ្សេងទៀត។

ក្រោយមក ព្រះចៅក្រុងអណ្ណាម ទាស់ទែងនឹងស្ដេចចិន ទើបទ្រង់ចាត់ព្រះរាជទូត នាំព្រះសុភអក្សរពីរច្បាប់ : មួយច្បាប់ឲថ្វាយព្រះចៅក្រុងកម្ពុជា មួយច្បាប់ទៀតឲថ្វាយព្រះអង្គចូវ ឲជួយក្រាបបង្គំទូល ព្រះស្វាមី សូមខ្ចីខេត្តកោះក្របីព្រៃនគរ ដើម្បីបង្ហាត់សេនាទាហាន ក្នុងរយះពេលតែ ៥ ឆ្នាំ តែប៉ុណ្ណោះ។ ព្រះរាជាខ្មែរ ទ្រង់យល់ឃើញថា ព្រះចៅក្រុងហ្វេ ជាបិតាក្មេងព្រះអង្គ និង ស្រុកយួន មានចងសម្ពន្ធមិត្ត តាំងពី រាជ្យព្រះបិតាមកម្លេះ ដែលជាទីពឹង នៃការកំហែងសៀម ដូច្នេះ ទ្រង់ ត្រាស់ព្រះចិន្ដា ឲយួនខ្ចី តាមសេចក្ដីស្នើ របស់ព្រះចៅក្រុងហ្វេទៅ។ ពួក

យួនក៏បានមកតាំងទីលំនៅ ប្រកបរបររកស៊ី នៅដែនដីកម្ពុជាតាំងពេលនោះមក។

រីឯព្រះចៅក្រុងទេពបុរី ស្រីអយុធ្យា នៃ នគរសៀម ព្រះនាម ថៃណា វិញ ទ្រង់ ព្រះចិន្តាថា ខ្មែរ រួមដៃ ជាមួយយួនកាន់តែខ្លាំងឡើងៗ ដោយបោះបង់ចោលសៀម ដែលទ្រង់ ទុកអំពើនោះជាការមើលងាយព្រះអង្គ ដូច្នេះ ទ្រង់ត្រាស់ឲកេណ្ឌទ័ព ១០ ម៉ឺននាក់ ដើម្បីមកវាយស្រុកខ្មែរ ដើម្បីផ្តាលផ្តាញ់ ព្រះរាជាខ្មែរ ឲរាងម្តង។ ព្រះចៅសៀម ដឹកនាំទ័ព ដោយខ្លួនឯង។ ទ័ពខ្មែរ ពើបពះប្រទះនិងទព័សៀម នៅខេត្តមហានគរ (សៀមរាប)។ តែទ័ពខ្មែរធ្វើល្បិចដកថយ រហូតមកដល់ខែត្របារាយណ៏។ នៅទីនោះទាហានសៀមផឹកទឹកជ្រោះ ទឹកព្រៃចំការ នាំកើតជម្ងឺគ្រុនចាញ់ ស្លាប់អស់ ១/៣។ ១/៣ ទៀត មានជម្ងឺ ដែលនាំទ័ពចុះទន់ខ្សោយជាខ្លាំង ហើយ តម្រូវ ដកថយក្រោយវិញ។ មកដល់ស្រុក នគរវត្ត បានជួបនឹងទ័ពខ្មែរ លើកគ្នាវាយពីក្រោយ។ ទ័ពសៀមស៊ូទ្រាំមិនបាន ក៏នាំគ្នារត់បែកគ្នា ទៅស្តាំផង ទៅឆ្វេងផង។ ទោះបី ព្រះចៅសៀម ត្រាស់បញ្ជា ឲសេនាទាហានខំប្រឹងទប់ទល់ឲមែនទែន ពុំនោះសោធ យើងនឹងស្លាប់ជាមិនខាន តែ ទ័ពសៀមទ្រាំពុំបាន ក៏បែករត់ខ្ចាត់ខ្ចាយអស់ទៅ។ ព្រះចៅ ថៃណា នាំរេហ៍ពលប្រមាណជា ១០០នាក់ រត់ត្រឡប់ទៅព្រះនគរវិញ តែ

ត្រូវទ័ពខ្មែរដេញតាមវាយ។ ទាហានស្ទិទ្ធ ១១នាក់ របស់ព្រះ ថៃណា នាំម្ចាស់ខ្លួន រត់ ទៅដល់ ម្លូព្រៃ តែត្រូវ ទាហានខ្មែរ ៦នាក់ ដេញជាប់ជានិច្ច។ ព្រះ ថៃណា ភិតភ័យពេកណាស់ ទើបទ្រង់ដោះព្រះមាលា(ខ្សែក) ដាំពេជ្យ របស់ព្រះអង្គ ហើយបោះទៅឲទាហានខ្មែរ ដែលកំពុងដេញតាម ប្រាប់ថា ឲឯងយករបស់នេះចុះ។ ខណៈនោះ នាយទាហានខ្មែរឃើញ ព្រះមាលាក៏បញ្ជាឲសេនាទាហានខ្លួនឈប់រើស។ ក្នុងពេលដែលទាហានខ្មែរ កំពុងតែរើសគ្រឿងពេជ្យនោះ ព្រះ ថៃណា ក៏ដកឃ្លាររត់រួចទៅ យាងត្រឡប់ទៅស្រុកសៀមវិញទៅ។

មកដល់ឆ្នាំ ១៦៣៣, ព្រះចៅ ថៃណា ឲកេណ្ឌទ័ព ៥ម៉ឺននាក់ ដឹកនាំដោយ ព្រះចៅវាំងណាម មហាឧបរាជ លើកតាមជើងទឹក មកវាយស្រុកខ្មែរ ម្តងទៀត។ មកដល់ខេត្តកំពង់សោម ហើយពុំឃើញទ័ពខ្មែរ សូម្បីតែបណ្តារាស្ត្រ ក៏គ្មានដែរ។ ទ្រង់ត្រាស់ឲទាហានរកចាប់មនុស្សបានម្នាក់មកសួរ។ ពេលនោះតាចាស់ ដែលនៅចាំភូមិនីមួយៗ ក៏ឆ្លើយថា រាស្ត្រខ្មែរ ទាំងនោះ ឮថា សៀមលើកកងទ័ពមកដល់ហើយនោះ ក៏ភ័យស្លុត ខ្លបខ្លាចអំណាច ពន់ពេក។ ឥឡូវហ្លួងខ្មែរ ឲបម្រើកេណ្ឌអ្នកស្រុក នាំគ្នារត់ចូលក្នុងព្រៃរលីងទៅហើយ។ ឮដូច្នេះ មេទ័ពសៀម ក៏សប្បាយក្នុងព្រះទ័យណាស់ ក៏បញ្ជាឲទ័ព លើកមកកាន់ ខេត្តកំពត។

មកដល់ទីនេះ ទ្រង់ឃើញស្ងប់ស្ងាត់ណាស់ដូចគ្នា។ ទ្រង់ចាត់កងទ័ព ឡើងមកលើគោក។ មកដល់ស្រុកកំពត ទព័សៀមជួបប្រទះនឹងទ័ពខ្មែរ ហើយចូលច្បាំងគ្នា ពុំទាន់បានប៉ុន្មានភ្លេងផង ទ័ពខ្មែរធ្វើជាដកថយរត់។ សៀមសម្រេីបចិត្ត ដោយឃើញទ័ពខ្មែររត់ ក៏លើកដេញតាមទៅដល់ ច្រកភ្នំខាងកើតទ្វារកំពត។ នៅទីនោះ ទាហានសៀម ឃើញបាយសម្លសាច់គោ ទើបនឹងដាំ នៅក្តៅហុយថ្មីៗ នឹកស្មានតែទ័ពខ្មែរ រត់ចោល។ ត្រូវនឹងខ្លួនកំពុងឃ្លានបាយ អស់កម្លាំងផង ក៏តាំងបោះទ័ពស៊ីបាយ។ ទាហានសៀម ស៊ីបាយមិនទាន់ទាំងបានប៉ុន្មានផង ក៏ពុលទាំងអស់គ្នា ប្រាសដេកថ្ងូរស្រែករោទ៍ ក្អួតចង្អោរ តែរាល់ខ្លួន។ លុះដល់ពេលអធ្រាត្រ ទ័ពខ្មែរ នៅពួនក្បែរទីនោះ ក៏ចេញវាយផ្ទប់ពីមុខពីក្រោយ ពីឆ្វេង ពីស្តាំ សម្លាប់ទាហានសៀម អស់ជាច្រើន។ ព្រះចៅវាំងណាម[3] មេទ័ពសៀម បាត់ នូវការត្រួតត្រា នៃកងទ័ព ក៏រត់ចុះទូកចម្បាំង ជាមួយ សេនាស្និទ្ធ វិលត្រឡប់ទៅស្រុកសៀមវិញ។ ទ័ពខ្មែរចាប់បានឈ្លើយសៀមជាច្រើន។ ព្រះរាជាខ្មែរ ទ្រង់ត្រាស់ឲបំបែកគ្នា នាំទៅស្រុកបាភ្នំខ្លះ ព្រៃនគរខ្លះ និង ភ្នំដើងបាដែងខ្លះ។

[3] ព្រះចៅវាំងណាម ពេលរត់វិលត្រឡប់ទៅស្រុកសៀម ទ្រង់តូចព្រះទ័យណាស់ ហើយក៏ក្សយព្រះជន្មតាមផ្លូវនោះទៅ។

ព្រះចៅ ថៃណា បានទ្រង់ជ្រាបសព្វគ្រប់ហើយ ទ្រង់ព្រះពិរោធណាស់ ទើបទ្រង់តាំងព្រះរាជបុត្រា ព្រះនាម ព្រះជេដ្ឋា ឲកេណ្ឌទ័ពជាថ្មី ៥ ម៉ឺននាក់ លើកតាមជើងទឹកមកវាយស្រុកខ្មែរ ម្តងទៀត។ ទ័ពសៀមមកដល់កំពតទ្រង់ ជំនុំការរាជការ ដើម្បីចង់ដឹង កម្លាំងសឹកទ័ពខ្មែរ។ លុះជំនុំហើយ ទើបទ្រង់ឲតែងតាំងសុភអក្សរ ចាត់មន្ត្រីទូត ឲនាំទៅជូន មេទ័ពខ្មែរ។ ក្នុងសំបុត្រនោះ មេទ័ពសៀម ស្នើសូម មេទ័ពខ្មែរ ឈប់សំរាកទ័ពចំនួន ១៥ ថ្ងៃមុននឹងចូលច្បាំងគ្នា។ ទូតសៀម មកដល់ បន្ទាយជ័យរបស់ទ័ពខ្មែរ ប្រគល់ថ្វាយ សម្តេចព្រះមហាឧបរាជ ព្រះឱទ័យ នូវសំបុត្រ របស់មេទ័ពខ្លួន។ អ្នកបកប្រែភាសា អានចប់កាលណា ទ្រង់ ត្រាស់ថា: ឯងត្រឡប់ទៅក្រាបទូលម្ចាស់ឯងចុះថា យើងព្រមតាមហើយ។ ពេលនោះ ទូតសៀម សង្កេតឃើញថា ទ័ពខ្មែរមានចំនួន បីដងលើសទ័ពសៀម ហើយ មាន សេះ ដំរី ក៏សន្ធឹកគឹកកងណាស់ហើយ ឃើញ កិរិយា សេនាទាហានខ្មែរ សង្កៀតធ្មេញ ចេញបំណាច់ចំណង ចង់តាំងច្បាំងនឹងសៀមខ្លាំងណាស់។ ទូតនោះ ក៏យកដំណឹងនេះ ទៅក្រាបថ្វាយទូលម្ចាស់ របស់ខ្លួន។ ដឹងដំណឹងនេះហើយ មេទ័ពសៀម ក៏ស្នើដល់ អស់រេពលខ្លួនថា ទ័ពយើងមានចំនួនតិចណាស់ បើចូលច្បាំងនឹងខ្មែរ នាំឲនឿយហត់ ស្លាប់សេនាទាហាន ឥតប្រយោជន៏។ ដូច្នេះយើងត្រូវតែត្រឡប់ទៅប្រុងប្រៀប

រៀបចំ ទ័ពជាថ្មី ម្តងទៀត ហើយសូមវិលត្រឡប់មកច្បាំងវិញ។ ទាហានសៀម ក៏ស្រែកទទួលយល់ព្រម ដូចគេហោចូលក្នុងពេលដែលធ្វើសឹកសង្គ្រាម។ មេទ័ពសៀម ទ្រង់បន្ថែមទៀតថា : បើយើងយល់ព្រមគ្នា ចុះសម្រុងនឹងគ្នាដូច្នេះហើយ ត្រូវឲនិយាយព្រមគ្នាថា ខ្យល់ព្យុះ បណ្តាលមានរលកខ្លាំង នឹងឆ្លងទៅពុំរួច។ ដល់យាមទីពីរ ក្នុងវេលាយប់ មេទ័ពសៀម ទ្រង់ត្រាស់បង្គាប់ឲសេនាទាហានចុះទូកចម្បាំង បើកក្តោងចេញពី ស្រុកខ្មែរជាប្រញាប់។ ដឹងដំណឹងនេះភ្លាម មេទ័ពខ្មែរ ស្នើដល់ព្រះរាជាខ្មែរ សូមលើកទ័ព ទៅវាយស្រុករសៀមតែម្តង ព្រោះយល់ឃើញថានគរនេះ កំពុងតែចុះខ្សោយ។ តែព្រះរាជាខ្មែរ ត្រាស់បង្គាប់ មិនឲបន្តសង្គ្រាមនឹងសៀម ធ្វើអ្វីទៀត ព្រោះ ព្រះនគរត្រូវចាំបាច់ រៀបចំឲមាំមួនសិន។ ចម្បាំង ទៅវិញទៅមក មិនចេះចប់ នាំឲ ប្រជានុរាស្ត្រ ពុំអាច ប្រកប កិច្ចការស្រែចំការ ឲបានបរិបូណ៌ឡើយ។

ពេលក្រោយមក ព្រះជ័យជេដ្ឋា ព្រះចៅក្រុងកម្ពុជា ទ្រង់បង្គាប់ឲនាំ ព្រះរាជបុត្រច្បង ព្រះនាមព្រះពញាតូ ចម្រើនព្រះជន្មវស្សាបាន ២១ ឆ្នាំ ទៅឲចូលបព្វជិតជាភិក្ខុ នៅនគរវត្ត។ ទ្រង់បានទំនុកបំរុង ព្រះចន្ទវតី ព្រះរាជបុត្រីឲជា ព្រះជាយាកំណាន់ព្រះទ័យ នៃចៅពញាតូ។ ថាបើទ្រង់សឹក ចាកសិក្ខាបទមក កាលណា ទ្រង់នឹង បង្វែរាជ្យ

ថ្វាយ ទៅព្រះពញា តូ និង ព្រះអង្គចន្ទវតី ជាព្រះទេពី។ ព្រះពញា តូ តាំងពីចូលបព្វជ្ជាជាភិក្ខុ កាលណាមក ស្ដេចខំប្រឹង ឱស្សាហ៍រៀនសូត្រ ពុំដែលធ្វេស រហូត ចេះចប់ ត្រៃភូមិ, ត្រៃភេទ ត្រៃយុគ, ព្រះត្រៃបិដក, ទ្រង់ គង់ជាសុខសប្បាយក្នុង អរិយសច្ចធម៌ ពុំចង់សឹក ចាកសិក្ខាបទ ឡើយ។ លុះដល់ ឆ្នាំ ១៦៣៧, ព្រះបិតា មានព្រះជន្ម ៤៩ ឆ្នាំ ស្ដេចព្រះឈួន ក៏ទ្រង់ សោយព្រះទីវង្គត ក្នុងឆ្នាំនោះទៅ។ នៅវេលានោះ ព្រះរាជវង្សានុវង្ស និង នាម៉ឺន សព្វមុខមន្ត្រីជំនុំព្រមយល់ថា : ព្រះពញា តូ ជាទាយាទ តែទ្រង់ នៅព្រះផ្នួសនៅឡើយ បើយើងនឹងអញ្ជើញស្ដេច ឲចាកសិក្ខាបទមក ក៏ពុំទាន់ ហើយ ព្រះរាជហឫទ័យ ក៏កំពុងតែស្រឡាញ់អាល័យសីលផ្នួសនោះពន់ប្រមាណ តែបើយើង អញ្ជើញព្រះអង្គ នូ ឬ ព្រះអង្គ ចន្ទ ជាបុត្រា របស់លួងសុវណ្ណកោដ្ឋដែរ ឲទទួលរាជសម្បត្តិនោះ ឃើញថាខុសនឹងច្បាប់ ដ្បិតថា ព្រះអនុជ ពុំត្រូវសោយរាជ្យ កន្លងព្រះជេដ្ឋាបានទេ។ ដូច្នេះគួរយើង អញ្ជើញ សម្ដេចព្រះឧទ័យ មហាឧបរាជ វិញ ដ្បិតថា សម្ដេច ព្រះបិតុលា (មាខាងឪពុក) ធ្លាប់កាន់កាប់កិច្ចការរាជការមកស្រាប់។ គិតព្រមគ្នាដូច្នេះហើយ ក៏នាំគ្នាចូលក្រាបបង្គំទូល ព្រះមហាឧបរាជ[4] តាមសេចក្ដីដែលបានគិត។ ទ្រង់ជ្រាប សេចក្ដីជំនុំ ទ្រង់ត្រាស់តបថា :

4 ព្រះមហាឧបរាជ មានបុត្រ ៤ ព្រះអង្គ ទ្រង់ព្រះនាម : ព្រះអង្គ នន្ទ, សូរ, តន់, តន្ទ។

កាលព្រះរៀម គង់ព្រះជន្មាយុនៅឡើយ ព្រះអង្គ ទ្រង់បម្រុងទុកថ្វាយ ព្រះពញា តូ ដូច្នេះ យើងពុំត្រូវធ្វើ ខុសព្រះរាជបណ្តាំ នោះឡើយ ហើយវា អនិយមនឹង ប្រពៃណីក្សត្រផង។ តែ ទ្រង់ យល់ព្រម ទទួលរក្សារាជសម្បត្តិ ទុកសិន ក្នុងឋានៈ ជា ព្រះមហាឧភយោរាជធំ ទំរាំ ព្រះពញា តូ ចាកសិក្ខាបទ។ សម័យថ្ងៃមួយ ព្រះឧទ័យ បានជួបប្រទះព្រះអង្គម្ចាស់ក្សត្រី ចន្ទវតី ដែលជាគូផ្សំផ្គុំ ជាមួយ ព្រះពញា តូ។ ទ្រង់ព្រះស្នេហាណាស់ ហើយ រកគ្រប់មធ្យោបាយដើម្បី លួងលោម ព្រះចន្ទវតី មកធ្វើជាទេពី រហូតបានសម្រេច ដូចប្រថ្នា។

រីឯ ព្រះពញា តូ វិញ តែងតែប្រកែក ពុំព្រមចាកសិក្ខាបទសោះ រហូតពេលមួយ ពួកភិលៀង ខាងព្រះអង្គ និយាយពន្យល់ទ្រង់ថា : បើទ្រង់ មិនស្រឡាញ់ រាជសម្បត្តិ គួរ ព្រះអង្គគិតដល់ ព្រះវររាជមាតាផង។ ឥឡូវ ព្រះមហាឧភយោរាជ ស្តេចប្រលោម យកព្រះអង្គចន្ទវតី ធ្វើជាទេពីបានរួចហើយ, ថ្ងៃមុខទៀត ស្តេចនឹងយករាជសម្បត្តិថែមទៀតជាពុំខាន។ បើដូច្នោះមែន មុខនាទី ជាសម្តេចព្រះវររាជមាតា ព្រះទាវ នឹងបានទៅខាងព្រះមាតា សម្តេចព្រះមហាឧភយោរាជ ទៀតជាពុំខាន។ គួរព្រះអង្គ អាណិតដល់ព្រះមាតា ដែលព្រះអង្គ លះបង់ស្រុកឃ្លួនមកហើយ ហើយនឹងបាត់ តួនាទីជា ព្រះវររាជមាតាទៀត។ ធ្វើបែប

នេះ គឺគេអាចទុកព្រះអង្គ ដូចជាមាន អកតញ្ញូធម៌នឹងព្រះមាតាក្រៃពេកណាស់។ ព្រះពញា តូ ក៏យល់ព្រមចាកសិក្ខាបទ តាមការស្នើ ដើម្បីទទួលរាជសម្បត្តិ បន្តពីព្រះបិតា។ ព្រះមហាឧភយោរាជ ទ្រង់យល់ព្រមតាមសព្វព្រះរាជហឫទ័យ ទ្រង់ ក៏អញ្ជើញ ស្តេច ឲឡើងគ្រងរាជ្យក្រុងកម្ពុជា តាមប្រពៃណី។ ស្តេច ទ្រង់ មានព្រះនាមរាជ្យ ព្រះស្រីធម្មរាជា។ ក្នុងឯកសារខ្លះថា ព្រះនាមរាជ្យពិត គឺ ព្រះបាទធម្មរាជ សំភារ។

ព្រះចៅអណ្ណាមកុក ទ្រង់ជ្រាបថា ព្រះពញាតូ ដែលជាចៅព្រះអង្គ បានឡើងគ្រងរាជសម្បត្តិ នៅស្រុកខ្មែរ ទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់។ ស្តេច ឲនាំ ព្រះរាជបណ្តាការ ទៅថ្វាយ និង រេហ៏ពល ៥០០ នាក់ទៀត សំរាប់ជួយធ្វើបុណ្យគ្រងរាជសម្បត្តិ។ ហើយទូល សុំឲតាំង ព្រះអង្គចូរ ជា សម្តេចព្រះទាវធីតា មហារាជជននី ឲមានអំណាចដ៏ខ្លាំងខ្លា អាចនិយាយការផែនដីបាន។ ព្រះស្រីធម្មរាជាយល់ព្រមតាមសេចក្តីស្នើ របស់ព្រះចៅអណ្ណាមកុក គ្រប់ប្រការ ព្រម ចាត់ទុកមន្ត្រីយួនពីរ នាក់ និង រេហ៏ពលទាំង ៥០០ នាក់ នោះ ឲនៅគាល់បម្រើ សម្តេចព្រះទាវធីតា មហារាជជននី។

ថ្ងៃមួយ ព្រះចៅពញា តូ ចូលគាល់ ព្រះមាតា និង ព្រះបិតុលា តាម ទំនៀមរាល់ឆ្នាំ។ ខណៈនោះ ទ្រង់ទតឃើញ

ព្រះចន្ទវតី ក៏នឹកក្នុងព្រះរាជឬទ័យ ភ្នែព្រះស្នេហាស្តាយអាល័យណាស់។ ទ្រង់ លួចទាក់ទងនឹង សាវឡឹកពីរនាក់ឈ្មោះនាង ចាន់ និង ថែម របស់ព្រះចន្ទវតី រួចធ្វើលិខិតអក្ខរាស្នេហា ឆ្លើយឆ្លង ជាមួយ គូសាងនឹងព្រះអង្គ រហូតដល់ ព្រះនាងចន្ទវតី លែងចង់រស់នៅ ក្នុងអំណាចព្រះស្វាមី តទៅទៀត ក៏គិតរកឧបាយកល នឹងរត់ទៅ រស់នៅជាមួយ ហ្លួង តូ នៅកោះឃ្លោក។ ថ្ងៃមួយ ព្រះចន្ទវតី ចូលទៅក្រាបបង្គំទូលព្រះស្វាមីថា ទ្រង់ធ្លាប់បានបន់ព្រះវត្តវិហារសួគ៌ កាលព្រះស្វាមីប្រឈួន ថាបើ ព្រះអង្គចាកព្រះរោគ នឹងសាងផ្កាប្រសាទដប់ នាំទៅថ្វាយ។ ព្រះឱទ័យមហាឧភយោរាជ ទ្រង់ពុំជ្រាបកលឧបាយ ក៏អនុញ្ញាត ឲព្រះទេពី យាងទៅធ្វើបុណ្យ តាមព្រះរាជបំណង។ ផ្លូវទឹកពីក្រុងឧដុង្គ ទៅ ព្រះវត្តវិហារសួគ៌ មានកន្លែងផ្លូវបែបទៅកោះឃ្លោក។ មកដល់កន្លែងនោះ ព្រះចន្ទវតី ត្រាសបញ្ជាដល់មន្ត្រីដែលតាមហែ ឲចែវព្រះទីនាំង ទៅចូលចតនៅកោះឃ្លោក ហើយ ទ្រង់ ក៏ចូលទៅនៅរួមនឹង ហ្លួង តូត្រកាលត្រកងស្នេហា តាមសប្បាយព្រះរាជហឫទ័យ ភ្លើនភ្លេចព្រះអង្គ បោះបង់សីល ៥ សីល ៨។ ជ្រាបហេតុដូច្នេះព្រះឧទ័យ ខ្ញាល់ណាស់ ទើបលើកទ័ពតាមចាប់។ ព្រះចៅពញា តូ លើកទ័ពមកតយុទ្ធវិញ។ ប៉ុន្តែព្រះអង្គថយកម្លាំងជាង ទើបទ្រង់គៀសខ្លួនរត់ចេញទៅ។ លុះដល់ស្រុកកញ្ជរ ខែត្រក្រចេះ ទ្រង់ក៏ឡើងពួន លើដើមត្នោត

មួយដើម។ ទ័ពព្រះឧទ័យតាមទាន់ ក៏បាញ់ព្រះអង្គត្រូវធ្លាក់ស្លាប់ ក្នុងព្រះជន្ម ៣០ វស្សា។ ព្រះចៅពញា តូ ទ្រង់សព្វព្រះទ័យ ខាងអក្សរសាស្ត្រណាស់ ទ្រង់បាននិពន្ធច្បាប់ផ្សេងៗ មាន ច្បាប់ព្រះរាជសំភារជាដើម ទុកទូន្មានកូនចៅជាន់ក្រោយ រហូតដល់សព្វថ្ងៃ។ បន្ទាប់ពី ហ្លួងទ្រង់រាជ តូ សុគត ទៅ, ព្រះឧទ័យ ក៏អញ្ជើញ ពញា នូ[5] ជាព្រះអនុជ និង ពញា តូ ឲឡើងសោយរាជសម្បត្តិ ស្នងព្រះជេដ្ឋា។

## ព្រះអង្គក្សត្រីចូវ

ព្រះអង្គចូវ កាលព្រះស្វាមី ទ្រង់គង់ព្រះជន្មនៅឡើយ ព្រះស្វាមី ទ្រង់បង្គាប់ មន្ត្រីឃួន ឲរកថ្នាំញៀនកម្លាំងផ្លូវភេទមកលាយជាព្រះឱសថថ្វាយ តែលាយពុំទាន់បាន ក៏ទ្រង់ប្រឈួន សោយទិវង្គតទៅ។ ថ្ងៃមួយនោះ ព្រះអង្គចូវ មានព្រះសវនីយ៍ ហៅហ្មនោះមកសួរថា : ថ្នាំនោះ តើប្រកបត្រូវនឹងរោគអ្វី ? ខណៈនោះ ហ្មពុំហ៊ានទូលចំ បែរជាក្រាបទូលបញ្ឆិតបញ្ឆៀងថា : ថ្នាំនោះ តែអាស្រ័យកាលណា នឹងកើតមានការសប្បាយរីករាយ ក្នុងខ្លួនណាស់ រកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ ទ្រង់ជ្រាបហើយ នឹកស្មានថាគេទូលដោយស្មោះត្រង់ ក៏ព្រះអង្គឲយកថ្នាំនោះមកសោយ។ លុះសោយទៅកាលណា យោនីនោះ ក៏រីកធំឡើង ហើយឡើង

[5] ព្រះស្រីសុរិយោព័ណ៌ មានព្រះរាជបុត្រា មកុដ ៣ ព្រះអង្គ : ព្រះពញា តូ, នូ និង ចន្ទ។

សម្រើបស្រើបស្រាលនោះ ពេកពន់ប្រមាណណាស់។ ចាប់តាំងពីពេលនោះមក ទ្រង់ឲរើសបុរសៗ ចូលគាល់តាមវេនជាអចិន្ត្រៃយ៏។ តែ មហាតលិកទាំងឡាយ ស្ដេចពុំសូវគាប់ព្រះទ័យនោះ ស្ដេចត្រាស់ឲបណ្ដេញចេញ ឬ ឲសម្លាប់ចោល ដើម្បីបំបាត់មាត់ក៏មាន។ រឿងអាថ៌កំបាំង របស់ម៉ែចូវនោះ ព្រះចៅពញា តូ ជ្រាបទាំងអស់ ទ្រង់ក្រែងរង្កៀសក្នុងព្រះទ័យ។ ព្រះអង្គ ពុំចង់គង់ នៅក្នុងក្រុងឧដុង្គ ជាមួយព្រះមាតា និង ព្រះបិតុលា ព្រះឧទ័យ ដែរ ក៏សម្រេចព្រះទ័យ លើកព្រះបរមរាជវាំង ទៅ កោះឃ្លោក។

ថ្ងៃមួយ ព្រះអង្គចូវ ស្ដេចទៅប្រពាតព្រៃ ទៅដាក់តាំងពន្លា នៅបឹងស្លែង ក្នុងខេត្តភ្នំពេញ។ ខណៈនោះ មានប្រុសម្នាក់ ជាកូនពញាសេនាធិបតី ចៅហ្វាយស្រុកខេត្តបរិបូណ៏ ឈ្មោះពញា ជំ។ បានជាប្រុសនោះ ឈ្មោះដូច្នេះ ព្រោះអ្នកនោះជំទាំងរូប ខាងក្រៅ និង ទាំងរូបខាងក្នុង។ ពញាជំ តែងតែនាំស្ម័គ្របក្សពួករបស់បខ្លួនដើររក បរបាញ់សត្វ ជាអចិន្ត្រៃយ៏។ ជាថៃ្ងដន្យ ពញាជំ បានជួប ព្រះអង្គចូវ ហើយក៏ចាប់ចិត្តស្នេហាទៅវិញទៅមក។ ពេលថ្ងៃមួយ ព្រះអង្គចូវ កំពុងដើរកំសាន្ត លំហែព្រះទ័យ ស្រាប់តែក្រឡេងឃើញ ពញា ជំ កំពុងឡើងបេះផ្លែឈើ ហើយរបូតសំពត់ លេចចេញប្រដាប់ខាងក្នុង ជំ វែង។ ទ្រង់មុខគួរឲពេញព្រះទ័យណាស់។ រីឯ ពញា ជំ វិញ ខំរកមធ្យោបាយ ឲ

បានចូលគាល់ ព្រះអង្គចូវ, ក៏សម្រេចចិត្ត នាំយកសត្វ ដែលខ្លួនដើរបរបាញ់ជាច្រើន ទៅថ្វាយព្រះអង្គ។ ព្រះអង្គចូវ ឃើញ ពញា ជំ មកគាល់ដូច្នេះ ក៏ឃាត់ ពញា នោះ ឲ នៅចូលក្នុងវេនយាម យប់នោះ។ ក្នុងរាត្រីនោះ ព្រះអង្គចូវ ទ្រង់ស្កប់ស្កល់ពេញព្រះទ័យ ពន់ប្រមាណ។ តាំងពីពេលនោះមក ព្រះអង្គចូវ និង ពញា ជំ ក៏សម្រេចចិត្ត រស់នៅជាមួយគ្នា ដូចជា ប្ដី ប្រព័ន្ធ ទៅ[6]។ តែពួកនាម៉ឺន ពុំសូវខ្លាច ពញា ជំ នោះសោះ ទើប ព្រះអង្គចូវ បញ្ញាតឲហៅ គូស្នេហានោះថា អ្នកស្ដេចខ្លួនជំ។

ព្រះអង្គចូវ ទ្រង់មានឥទ្ធិពលខ្លាំងណាស់ ក្នុងកិច្ចការរាជការខ្មែរ តាំងពីព្រះស្វាមីព្រះអង្គ នៅមានព្រះជន្មនៅឡើយ។ ព្រះអង្គ មានសេនាឃ្មួន ការពារទ្រង់ ទាំងយប់ថ្ងៃ។ ទោះបី ព្រះស្វាមី សោយទិវង្គតទៅក៏ដោយ, ព្រះមហាឧភយោរាជ សម្ដេចឧទ័យ ដែលជា អ្នករក្សារាជសម្បត្តិ ឬរាជានុសិទ្ធិ មិនហ៊ាន ប៉ះពាល់ បុព្វសិទ្ធិព្រះអង្គឡើយ ព្រោះទ្រង់ ញញើត ព្រះចៅអណ្ណាម នឹងបង្កជម្លោះនឹងស្រុកខ្មែរ ដែលកំពុងមានជម្លោះនឹងស្រុកសៀម។ កាលមានជម្លោះដណ្ដើម ព្រះចន្ទវតី ជាមួយ ព្រះចៅ តូ, ព្រះឧទ័យ គ្មានបំណងនឹង សម្លាប់ ពញា តូ នោះទេ តែ មេទ័ព របស់ព្រះ

---

6 ព្រះអង្គចូវ រស់នៅជាមួយ ពញា ជំ រហូត សុគត បានព្រះជន្ម ៦១ ឆ្នាំ។ ក្រោយពី ព្រះអង្គ សុគតទៅ ពញា ជំ មានក្ដីរលីកនឹកអាល័យ ព្រះអង្គចូវណាស់។ ក៏ទៅរស់នៅ ខេត្តបាទី ហើយ នៅទីនោះ ក៏ឲសាងនូវចម្លាក់ យោនីពីថ្ម ហើយជីកត្រពាំងមួយ សង់សាលា សម្រាប់ដំកល់រូបចម្លាក់ នោះ។

អង្គជាជនជាតិព័រទុយហ្គេស៍ ឈ្មោះកាឃីណាតូ (Gallinato) ដែលនាំសេនាទាហាន ដេញតាម ពញា តូ ហើយ ទាហានព័រទុយហ្គេស៍ម្នាក់ លោះកៃកាំភ្លើង បាញ់ទៅត្រូវព្រះចៅខ្មែរ ធ្លាក់ពីចុងត្នោតមក ហើយសុគតទៅ។ តែមរណភាពជាគ្រោះថ្នាក់នោះ ក៏មានប្រយោជន៍ដល់ ព្រះឧទ័យនោះដែរ ព្រោះទ្រង់ មិនមែនជាអ្នកទទួលខុះត្រូវផ្ទាល់ ហើយអំពើ ព្រះចៅ តូ ក៏អាចចាត់ទុកជា ទង្វើទុច្ចរិត តាមផ្លូវសីលធម៌ និង ព្រះពុទ្ធសាសនាផង ព្រោះ ពញា តូ ទ្រង់ធ្លាប់បួសជាសង្ឃ។ ចំណែក ព្រះអង្គចូវ ទ្រង់ជ្រាបពីមរណភាព នៃព្រះរាជបុត្រ និង រឿងរ៉ាវទាំងឡាយ ទ្រង់ក៏នៅស្ងៀម ព្រោះបើបង្កជម្លោះនឹង ព្រះឧទ័យ ក៏គ្មានប្រយោជន៍អ្វីច្រើននោះដែរ សំរាប់ព្រះអង្គផ្ទាល់ និង ស្រុកយួន។

លុះដល់ឆ្នាំ ១៦៤៩, ព្រះហ្លួងទ្រង់រាជ្យ នូ មានព្រះទ័យ ចង់ដោះស្រាយ រឿងយួនខ្ចីខេត្តកោះក្របី ព្រៃនគរ ព្រោះ រយៈពេលខ្ចី វាហួសឆ្ងាយណាស់មកហើយ។ នៅក្នុងរាជជំនុំមួយដែលមាន ព្រះអង្គចូវ ចូលរួមផង ព្រះចៅ នូ ក៏លើករឿងនោះ មកចោទជាបញ្ហា។ តែពេលនោះ ព្រះអង្គចូវ ធ្វើអន្តរាគមន៍ យ៉ាងម៉ឺងម៉ាត់ថា : រឿងដែនដី ព្រៃនគរមួយនោះ មានសុភអក្សរព្រះចៅក្រុងអណ្ណាមកុក មកសម្តេចព្រះវររាជបិតា និង មកដល់អ្នកថា : ស្រុកចិន និងយួនមានកើតសង្គ្រាមនឹងគ្នា ពុំទាន់ដាច់ស្រេចនៅឡើយ ថា

សូមអង្វរករកូនសិន កុំអាលចេតឹងទាររឡើយ ហើយផែនដីមួយនេះ អ្នកម្ដាយ (ម្ដាយចុង) សូមជានា មិនចេខូចខាតបាត់បង់ទៅណាទាល់តែសោះ។ ខ្លួនអ្នកម្ដាយនេះ ក៏នៅក្នុងអំណាចកូនស្រាប់ បើដីនេះ ត្រឡប់បែរទៅជាខូចខាត ដោយប្រការ ដូចម្ដេចទៅវិញ អ្នកម្ដាយថ្វាយខ្លួនកូនចេតាមតែកូនធ្វើទោសអ្នកម្ដាយចុះ។ ព្រះចៅ នូ ទ្រង់ព្រះសណ្ដាប់ហើយ ក៏ទញ់ទាល់ព្រះអង្គណាស់ ហើយដោយទ្រង់ក្រែងព្រះរាជហឫទ័យ ព្រះអង្គ ចូវ ណាស់ដែរ ក៏ទ្រង់សណ្ឋិតនៅស្ងៀមទៅ។ លុះដល់ឆ្នាំ ១៦៥០, ទ្រង់ ចម្រើនព្រះជន្មបាន ២៧ ឆ្នាំ, គម្រប់រាជ្យបាន ៥ ឆ្នាំ, ទ្រង់ ព្រះឈួនរោគជាទម្ងន់ ទ្រង់សុគតទៅ។

លើកនេះ ព្រះឧទ័យ មិនយល់ព្រម ប្រគល់រាជសម្បត្តិ ដល់ព្រះរាជបុត្រពៅ ព្រះស្រីសុរិយោព័ណ៌ ព្រះនាម ព្រះអង្គចន្ទទៀតឡើយ។ ព្រះអង្គ ស្នើដល់អស់មន្ត្រីទាំងពួង ប្រគល់រាជសម្បត្តិ ចេបុត្រច្បងព្រះអង្គ ព្រះនាម នន្ទ ចម្រើនព្រះជន្ម ២០ ឆ្នាំ។ ដោយពួកមន្ត្រីទាំងនោះ មានសេចក្ដីស្រឡាញ់ ព្រះឧទ័យផង ក៏ព្រមគ្នា តាមរាជសំណើរនោះទៅ។ បំលាស់ប្ដូរ ខ្សែរាជ្យនោះឯង ដែលនាំ ព្រះអង្គចន្ទ ជាមេទ័ពខ្មែរល្បីម្នាក់ ទ្រង់តូចព្រះទ័យណាស់ ហើយគិតឧបាយជាមួយ ស្ដ័គ្របក្សព្រះអង្គ នឹង ដណ្ដើមរាជ្យ ចេបានជាដាច់ខាត។ លុះដល់ឆ្នាំ ១៦៥៣, ព្រះអង្គចន្ទ ក៏នាំសេនា

ទៅលុកផ្ញើគត ព្រះចៅ នន្ទ និង ព្រះឱទ័យ មហាឧភយោរាជ បានដូចសំរេច ហើយឡើងសោយរាជសម្បត្តិចម្រើនព្រះជន្ម ២៣ ឆ្នាំ។ ក្នុងឯកសារខ្លះ គេ សរសេរ ព្រះនាម ព្រះអង្គចន្ទ ថា ព្រះសត្ថា (១៦៥៣-១៦៥៦)[7]។

លុះដល់ឆ្នាំ ១៦៥៥, ព្រះរាជាខ្មែរ មានបំណងទៅទៀមទារខេត្ត ព្រៃនគរ ពីយួនវិញ តែ នៅពេលប្រជុំ ព្រះអង្គ ចូវ ផ្ញើអន្តរាគមន៍ ជាថ្មីម្តងទៀតថា : ស្រុកព្រៃនគរមួយនេះ អ្នកសុំឲយួននៅសំណាក់អាស្រ័យ គ្រាន់នឹងមករកអ្នកទម្រាំអ្នក អស់ជីវិត។ ឯខេត្តទាំង៥[8] សម្រាប់ឡើងអ្នក[9] នោះ ឲអ្នកយកជាសម្រាប់រាជ្យចុះ ទុកតែខេត្តព្រៃនគរមួយនេះ ឲឡើងខ្លួនអ្នកតទៅ។ ទើបព្រះអង្គចន្ទ ឬ សត្ថា ទ្រង់ទញ់ទាល់ហើយក៏បង្អង់សេចក្តីនឹងទារនោះរៀងមក។

ក្រោយបន្តិចមក ព្រះអង្គ ចូវ ចូលថ្វាយបង្គំ ព្រះចៅខ្មែរ សុំទៅរស់នៅ ភ្នំពេញ ដោយនាំ បុត្រ សពព្រះឧទ័យ ព្រះអង្គ សួរ និង តន់ ទៅជាមួយផង។ ហ្លួងទ្រង់រាជ្យ ពុំហ៊ាមទទឹងនឹងសំណើរនេះឡើយ ហើយក៏អនុញ្ញាត តាមព្រះរាជហឫទ័យ ព្រះអង្គ ចូវ ទៅ។

---

7 ព្រះអង្គនេះឯង ដែលយល់ព្រម ចូលសាសន៍ចាម ដោយស្នេហា ព្រះទេពី ឈ្មោះ អ្នកម្នាង វ៉ះ ក្រៃពេក។

8 ខេត្តទាំង៥នោះ គឺស្ថិតនៅក្នុងទឹកដីកម្ពុជាក្រោម។

9 ពាក្យអ្នកនេះ ខ្មែរច្រើននិយាយថាម្តាយ និង សម្រាប់ហៅ ជាការគួរសម ចំពោះជនណាម្នាក់ផង។

ក្រោយមកទៀត ព្រះអង្គ ចូវ ទ្រង់ ជួយ ព្រះអង្គ សូរ និង តន់ ឲកេណ្ឌទ័ព វាយដណ្តើមរាជ្យពីព្រះសត្ថា។ ព្រះអង្គ សុំជំនួយទ័ពយួន ពីព្រះបិតា ឲមកជួយច្បាំង ស្តេចពីរអង្គនោះ រហូតចាប់ខ្លួន ព្រះសត្ថាបាន ហើយដាក់ទ្រុងដែកនាំខ្លួនទៅស្រុកយួន។ មេទ័ពយួន មិនត្រឹមតែ ចាប់ ព្រះមហាក្សត្រខ្មែរ ថែមទាំង មានបំណងនឹងចាប់ ព្រះអង្គ សូរ និង តន់ ទៀត ដើម្បី យកស្រុកខ្មែរ ដាក់ជាចំណុះតែម្តង។ តែស្តេចទាំងពីរអង្គដឹងខ្លួនទាន់ ក៏នាំទ័ព និង ព្រះអង្គចូវ ជាចំណាត់ខ្មាំង ផង ទៅក្រុងឧដុង្គ។ នៅទីនោះ ស្តេចទាំងពីរ បាន បញ្ចុះបញ្ចូល ទ័ពហ្លួង ឲរួបរួមជាមួយ ព្រះអង្គ ហើយនាំគ្នា វាយទ័ពយួន រហូតបានជ័យជំនះ។ ព្រះចៅក្រុងអណ្តាម ជ្រាបថា ព្រះអង្គចូវ ជាបុត្រី នៅក្នុងកណ្តាប់ដៃខ្មែរ ទ្រង់ក៏ដោះលែងព្រះសត្ថា ឲវិលត្រឡប់មកស្រុកខ្មែរវិញ។ តែតាមផ្លូវ ព្រះអង្គ មានជម្ងឺអហិវាតរោគ (រោគកើតអំពីខ្យល់នាំឲ ចុះផង ក្អួតផង) ទ្រង់ សុគតនៅស្រុកបត់ចិញ្ចៀន នៅក្នុងព្រះជន្ម ៤១ ឆ្នាំ[10]។

10 ចាប់ពីរាជ្យ ព្រះអង្គ សូរ (១៦៥៦-១៦៧១) មក ស្តេចខ្មែរ តែងតែឈ្លោះដណ្តើមរាជ្យគ្នា ហើយ ទៅសុំជំនួយទ័ពយួន ដើម្បីជួយច្បាំង។ រហូតមកដល់រាជ្យ ព្រះអង្គអឹម ទើបសៀម ចាប់ផ្តើមជ្រៀតជ្រែក មកលើស្រុកខ្មែរ ឡើងវិញ ព្រោះព្រះបាទធម្មរាជា ទី២ (១៧០៦-១៧១០) ដែលព្រះអង្គអឹម វាយដណ្តើមរាជ្យបាន រត់ទៅស្រុកសៀម ហើយសុំឲសៀមជួយច្បាំង យករាជ្យវិញ។

## អត្ថធិប្បាយ

### រូបឆោមល្អ និង ប្រាជ្ញា ព្រះអង្គចូវ

ព្រះអង្គម្ចាស់ក្សត្រី ចូវ ជា ស្តេចក្មេងម្នាក់ មានប្រាជ្ញាណាស់។ ទោះបី ព្រះអង្គ មករស់នៅក្នុងអំណាច នៃ ព្រះរាជវង្សានុវង្សខ្មែរ, ក្នុងបរិស្ថាន នៃ អស្ថិរភាព នៃរាជសម្បត្តិក្រុងកម្ពុជា, រាជជម្លោះហិង្សា រវាងស្តេចខ្មែរ ហើយ ទ្រង់ស្ថិតឆ្ងាយ ពី ព្រះនគរ និង បិតាព្រះអង្គ ទៀត តែ ទ្រង់អាចរក្សា នូវស្មារតីរឹងមាំណាស់ នៅចំពោះមុខគ្រប់ព្រឹត្តិការណ៏ ដែលទ្រង់ជួបប្រទះ។ មិនតែប៉ុណ្ណោះ ព្រះអង្គតែងតែមានដើមគំនិត រហ័សណាស់ ជាប្រតិកម្ម ដើម្បី ការពារនូវប្រយោជន៏នគរយួន និង ព្រះបិតា។ ក្នុងឯកសារប្រវត្តិសាស្ត្រខ្មែរ គេពុំបានរៀបរាប់ អំពី រូបឆោម របស់ព្រះអង្គទេ តែ បើយោង តាម រាគត្តិ (តម្រេកតណ្ហា) របស់ព្រះស្វាមី ខំរកថ្នាំជួយកម្លាំងកាមយោគ ដើម្បី បំរើ ព្រះទេពី និង ស្តាប់ ហើយ យល់ព្រមគ្រប់យោបល់ផង, ការណ៏នេះ គេអាច សន្និដ្ឋានបានដែរថា ព្រះស្វាមី ច្បាស់ជាស្រឡាញ់ព្រះអង្គចូវណាស់ ព្រោះ ព្រះទេពី មានរូបឆោមល្អពិសេស។ មួយទៀត ពញា ជំ ដែលជាគូស្នេហា របស់ព្រះអង្គចូវក្រោយពី ព្រះជ័យចេស្ដា ទ្រង់សុគតទៅ បានជួបប្រទះព្រះអង្គចូវ ក៏ចាប់ចិត្តស្នេហាខ្លាំងណាស់ ហើយក្រោយបន្តិចមក បានឃើញ ឆោមសុដន ជាថៃដន្យ ហើយនិយាយប្រៀបប្រដូចនឹង រស្មី ៣ ពណ៌ ជា គំនិត ស្រមៃ គឺអាច

បញ្ជាក់បាន នូវភាពរួបរួម នៃ រូបឆោមល្អ ពិសេស របស់ព្រះអង្គចូវ ដែលព្រះស្វាមី មើលឃើញនោះដែរ។ រូបឆោមល្អ និង ប្រាជ្ញា របស់ព្រះអង្គ ចូវ នោះឯង ដែលជាអាវុធស័ក្តិសិទ្ធ សំរាប់ការពារប្រយោជន៍ ស្រុកយួន និង ព្រះបិតាព្រះអង្គ។ អាវុធនេះ ដែល យួន តែងតែ យកមកប្រើនៅស្រុកខ្មែរ ប្រកបដោយជោគជ័យ គ្រប់សម័យ បន្តមកទៀត។

## និមិត្តរូប នៃ ទុព្វលភាពប្រុសខ្មែរ

ដូច្នេះ ស្ត្រីយួន ក្លាយជា និមិត្តរូប នៃ ទុព្វលភាពប្រុសខ្មែរ ដែល បុព្វបុរសខេមរា តាមរយៈប្រវត្តិសាស្ត្រជាតិ តែងតែទុក ព្រះជ័យចេស្តា ឬ ព្រះជ័យជេដ្ឋាទី២ ជា ជិពរូបភាព (image vivante) នៃ ទុព្វលភាពនោះ ដែលវានាំឲបាត់ទឹកដី កម្ពុជាក្រោម។ តែតាមពិត ព្រះអង្គ មិនមែនជាអ្នកទទួលខុសត្រូវ តែម្នាក់ឯងនោះឡើយ។ វាគឺជា ការទទួលខុសត្រូវទាំងស្រុង នៃ ប្រព័ន្ធ នៃ រាជានិយម ចាប់ពី សតវត្សរ៍ ទី១៧ មក ដែលនាំឲបាត់បង់ទឹកដីជាតិ ទាំងខាងលិច និង ខាងកើត។

## ឆ្លួតស្រី

ឆ្លួតស្រី ជាជម្ងឺ មានចំណាស់ ចាស់ស្មើនឹងពិភពលោក។ ដូចយ៉ាង ព្រះសត្ថា ឆ្លួតនឹង នាង វ៉ះ ស្រីចាម សុខចិត្ត ដូរសាសនា នាំបំផ្លាញរាជសម្បត្តិ និង ព្រះចៅពញា តូ ព្រោះ

តែស្រី មាន តណ្ហាអសុចិ ទ្រង់ ត្រូវបាត់បង់ជីវិតអសារ នឹងអរុធ។ តែ ជូនកាល គេទុក ស្ត្រី ជា អវិចិ ជួនកាល ជា ឋានសួគ៌ នៃ ប្រុស។ ដូច កវីជនជាតិបារាំងដ៏ល្បីម្នាក់ ឈ្មោះ Charles Baudelaire គាត់តែងកំណាព្យ អំពី កុសល និង អកុសល នៃ ស្ត្រី :

Imbécile – de son empire

Si nos efforts te délivraient,

Tes baisers ressusciteraient

Le cadavre de ton empire !

(Extrait du poème intitulé le Vampire)

អាឆ្កួត - ចក្រអ្នក

ប្រសិនយើងជួយ

តែកាមយោគអ្នក

ប្រោះបានតែខ្មោច

Mère des souvenirs, maîtresse des maîtresses,

O toi, tous mes plaisirs ! ô toi, tous mes devoirs !

(Extrait du poème intitulé le Balcon)

មាតា នៃអនុស្សាវរីយ៍, ឧត្តមម្ចាស់ចិត្ត នៃម្ចាស់ស្ត្រីទាំងឡាយ,

ឱ ស្ងួន, អូនគឺជា គ្រប់សេចក្តីសុខ របស់បង! ឱ ស្ងួន, អូនគឺជា គ្រប់បំណុល របស់បង !

ដូច្នេះ ស្ត្រី ជា សញ្ញា នៃ បំណង នៃតណ្ហា, កាមយោគ នៃ ទុក្ខ តែក៏ជា សញ្ញា នៃបុរិបុណ្ណសុខ (bonheur absolu) នៃ បុរសដែរ។ ព្រំដែន នៃ សេចក្ដីសុខ នឹង ទុក្ខ គឺស្ថិតនៅលើ ធាតុ នៃ បុរស-ស្ត្រី និង អំពើ នៃសេចក្ដីស្នេហា របស់ បុរស-ស្ត្រី។ ធាតុនោះ តាមធម្មជាតិ វាជា សេចក្ដីស្នេហា បរិសុទ្ធ ចាំបាច់ សំរាប់ជីវិត។ តែអំពើ នៃសេចក្ដីស្នេហា វា គ្រប់គ្រងដោយតណ្ហា ដូច្នេះ ត្រូវមាន សុមេធា[11] ដើម្បី រក្សា នូវសមតា នៃ អំពើ នៃសេចក្ដីស្នេហា។ សមតានោះ ឯង វាជា ព្រំដែន នៃ សេចក្ដីសុខ នឹង ទុក្ខ។ សេចក្ដី ស្នេហា បើគ្មាន តណ្ហាសោះ ក៏វាមិនពិតជា សេចក្ដីស្នេហា ដែរ តែ បើមាន តណ្ហាហួសហេតុពេក វាអាចនឹងនាំមក នូវ ទុក្ខ ដូច ព្រះជ័យជេដ្ឋាទី២, ព្រះសត្ថា និង ព្រះអង្គ ចូវ។

## តើ ព្រះអង្គ ចូវ ជាអកុសល ?

សួរថា តើ ព្រះអង្គ ចូវ ជា អកុសល នៃ សេចក្ដីស្នេហា ? ព្រះ អង្គ ចូវ ថ្វាយ នូវគ្រប់សេចក្ដីសុខ ដល់ស្វាមី។ ការណ៍នេះ ជា កតញ្ញូកិច្ច នៃ ភរិយា។ ព្រះជ័យជេដ្ឋាទី២ ទ្រង់ស្នេហា ព្រះទេពីណាស់ ព្រោះព្រះអង្គ ចូវ មាន គុណសម្បត្តិ ជា ភរិយាល្អ។ សេចក្ដីស្នេហានេះ ជាបំណុល របស់ស្វាមី ដល់ ភរិយា។ ដូច្នេះ អំពើនៃសេចក្ដីស្នេហា នៃគូនោះវាជា បដិការ ធម្មតា។ ដូច្នេះ ព្រះអង្គ ចូវ មិនមែន ជា អកុសល នៃ សេ

[11] ប្រាជ្ញាដែលអាចកម្ចាត់កិលេសបាន។

ចក្តីស្នេហា នោះទេ។ ម្យ៉ាងមួយទៀត នៅ ត្រង់ ព្រះអង្គ ផ្ទៀត យកតួនាទីទ្រង់ ជា ព្រះអគ្គមហេសី និង ព្រះមហារាជជននី នៃក្រុងកម្ពុជា ជ្រៀតជ្រែក ក្នុងកិច្ចការនគរ ដើម្បី ការពារប្រយោជន៍ ស្រុកកំណើត របស់ទ្រង់ គឺស្រុកយួន តើអាចទុកវាបានជា ការក្បត់។ នៅត្រង់ចំណុចនេះ វាមាន ភាពចម្រូងចម្រាស ព្រោះថា អាពាហ៍ពិពាហ៍ ព្រះអង្គ ចូវ ជាមួយ ព្រះជ័យជេដ្ឋាទី២ ជាសម្ពន្ធ សម្រុះសម្រួល រវាង ស្រុកខ្មែរ និង ស្រុកយួន ដើម្បី ចងសម្ព័ន្ធមេត្រី រវាងប្រទេសទាំងពីរ ដូច្នេះ ព្រះអង្គ ចូវ ទ្រង់មានតួនាទី ជា មន្ត្រីទូត ប្រចាំស្រុកខ្មែរ ដើម្បី ការពារប្រយោជន៍ ស្រុកយួន នៅក្នុង ក្របខណ្ឌទូត។ គ្រប់កាលៈទេសៈ ដែលទ្រង់ ការពារ ប្រយោជន៍យួន គឺទ្រង់ធ្វើឡើង ចេញមុខ ជា សំណើរសាធារណៈ ដល់ ព្រះមហាក្សត្រខ្មែរទាំងឡាយ ហើយ ព្រះចៅខ្មែរ តែងតែ ទទួលយល់ព្រមជានិច្ច។ តើនរណា ជា អ្នកទទួលខុសត្រូវ ?